

ព្រះចៅអធិការវត្ត ( រូបថត នាយកឹប)

វត្តព្រះស្រះស្រង់រងគ្រោះដោយការដាក់រំសេវបំផ្ទុះយកថ្មភ្នំ

ខេត្តកំពត : វត្តគីរីគុហាព្រះស្រះស្រង់ ភ្នំទទុង ទូកមាស នៅស្រុកបន្ទាយមាស បានរងការខូចខាតជាបន្តបន្ទាប់ ដោយសារតែការដាក់គីបរំសេវបំផ្ទុះបំបែកថ្មយកទៅផលិតស៊ីម៉ង់ត៍ ។ បើតាមការពិនិត្យ វត្តគីរីគុហាព្រះស្រះស្រង់នេះ គឺជាកន្លែងស្ងប់ស្ងាត់នៅជាប់នឹងជើងភ្នំ ហើយបើគេក្រឡេកមើលទៅលើភ្នំចំតែម្តង គឺមានរូងប្រាសាទគុហា ព្រះបុរាណមួយផងដែរ ។

នៅក្នុងរូងប្រាសាទខាងលើនេះ មានវត្ថុបុរាណជាច្រើន ប៉ុន្តែកាលពី១០ឆ្នាំមុន មានក្រុមចោរឡើងទៅរុករក ថែមទាំងលួចព្រះបដិមាធ្វើអំពីដើមរាំងយកទៅបាត់អស់ ។ តាមចៅអធិការវត្តនាមអ៊ុំ ឡាន ព្រះជន្ម៨១ឆ្នាំ បានមានថេរដីកាថា វត្តគីរីគុហាព្រះស្រះស្រង់ភ្នំទទុងទូកមាសនេះល្បីឈ្មោះជាយូរឆ្នាំមកហើយ ញាតិញោម ទាំងឡាយដែលមានវិបត្តិផ្លូវចិត្ត ឬមានគ្រោះអាសន្នអ្វីមួយតែងតែមកបែបន់ សុំសេចក្តីសុខ ឬក៏សំរាក នៅទីនេះមួយយប់ ។ បច្ចុប្បន្ន វត្តគីរីគុហាព្រះស្រះស្រង់នេះ មានព្រះសង្ឃតែ២អង្គ និងដូនជីម្នាក់ប៉ុណ្ណោះ ដែលកាលពីមុនក៏មានព្រះសង្ឃច្រើនអង្គគង់នៅដែរ តែដោយសារមិនមានចង្ហាន់ឆាន់ ព្រះសង្ឃបាននិមន្ត ចេញអស់ ។ ចៅអធិការវត្តមានថេរដីកាបន្តថា ពេលនេះសំណង់ក្នុងវត្តបានរងការខូចខាតដំបូល ជាច្រើន កន្លែង ដោយសារគេដាក់បំផ្ទុះយកថ្ម ។ ផ្ទាំងថ្មទាំងនេះបង្កឱ្យធ្លុះធ្លាយដំបូលជាបន្តបន្ទាប់ដូចជា សាលាឆាន់ និងកុដិ ហើយក៏ត្រូវអ្នកមើលការខុសត្រូវនៅរោងចក្រមកជួសជុលសង់ឱ្យវិញដែរ ។ ព្រះចៅអធិការដែល មានវ័យជរាណាស់ទៅហើយ មានថេរដីកាទៀតថា វាមានការលំបាកដែរ ឥឡូវនេះដោយសារ

តែគ្មានពុទ្ធបរិស័ទ ដែលធ្វើឱ្យព្រះសង្ឃអាចដាច់ចង្ហាន់ ម្យ៉ាងភ័យព្រួយពីរឿងថ្មខ្ចាត ឬធ្លាក់មកពីលើភ្នំអាចនឹងមានគ្រោះថ្នាក់ជាយថាហេតុ ។



ដូនជីដែលមានវ័យជរាទៅហើយ

ដូនជីឈ្មោះ សែម គីម អាយុ ៨០ឆ្នាំ និយាយថា គាត់មានដើមកំណើតជាខ្មែរកម្ពុជាក្រោម មិនមាន បងប្អូនកូនចៅទេ និងបានមករស់នៅក្នុងវត្តគិរីគុហាព្រះស្រះស្រង់ ភ្នំទទុងនេះ រយៈពេល៣០ឆ្នាំហើយ ហើយកាលពីនៅមានកំលាំង គាត់បានឡើងទៅបោសសំអាតនៅរូងប្រាសាទជារៀងរាល់ថ្ងៃ ឥឡូវនេះគាត់ ជរាឡើងទៅសំអាតលែងកើតហើយ ។ គាត់បន្តថា វត្តនេះបើរាប់ឈ្មោះចៅ អធិការគឺមាន១២អង្គហើយ ។

ចំណែកបញ្ហា គេបំផ្ទុះថ្មគឺមានរាប់រយរន្ធម្តង១ ហើយនៅពេលបំផ្ទុះនោះទាំងលោកយាយ ទាំងព្រះសង្ឃ នាំគ្នាទៅពួននៅក្រោមវិហារថ្មី តែជួនពេលខ្លះគេមិនបានប្រាប់ឱ្យដឹងធ្វើឱ្យលោក យាយស្រឡាំងកាំង ។ ដូនជីរូបនេះនិយាយទៀតថា ជីវិតចុងក្រោយរបស់លោកយាយ អាចនឹងស្លាប់នៅវត្តស្រះស្រង់នេះ ព្រោះ គ្មានសង្ឃឹមអ្នកណាក្រៅតែពីដេកចាំតែសង្ឃវ័យក្មេងមួយអង្គ និមន្តចេញទៅបិណ្ឌបាតប៉ុណ្ណោះ ។



ទិដ្ឋភាពក្នុងទីអារាមដែលមានរូបប្រាសាទបុរាណ

លោក ជា ចាន់លី អភិបាលស្រុកបន្ទាយមាស មានប្រសាសន៍ថា ការបាញ់រំសេវបំផ្ទុះ គឺក្រុមហ៊ុនមាន អាជ្ញាប័ណ្ណស្រប ច្បាប់ តែលោកមិនបានបញ្ជាក់ថា ទោះបីមានអាជ្ញាប័ណ្ណត្រឹមត្រូវក្តី តើផលប៉ះពាល់នេះ ត្រូវធ្លាក់ទៅលើអ្នកចេញ អាជ្ញាប័ណ្ណ ឬអ្នកទទួលអាជ្ញាប័ណ្ណ។ លោកគង់ ផល្លា ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ធ្លាប់មានប្រសាសន៍ថា រូងប្រាសាទនៅភ្នំទទុងទូកមាស គឺសាងសង់មុនសម័យអង្គរ ហើយស្រះស្រង់នៅជាប់នឹងភ្នំក៏មនុស្សសម័យដើមជីកដែរ ដូច្នេះគប្បីត្រូវគិតគូរពីការអភិរក្សផង ។

ប្រភពព័ត៌មានៈ   សារព័ត៌មានកោះសន្តិភាព

ថ្ងៃច័ន្ទ ១៣កើត ខែមិគសិរ ឆ្នាំឆ្លូវ ឯកស័ក ព.ស.២៥៥៣ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា គ.ស.២០០៩